# អនុសញ្ញាស្តីពី
# ការចែកចាយសញ្ញាដែលមានកម្មវិធីបញ្ជូនតាមផ្កាយរណប

ធ្វើនៅទីក្រុងប្រ៊ុយសែល ចុះថ្ងៃទី២១ខែឧសភាឆ្នាំ១៩៧៤

រដ្ឋហត្ថលេខីទាំងឡាយ

ដោយដឹងថា ការប្រើប្រាស់ផ្កាយរណបសម្រាប់ចែកចាយសញ្ញាដែលមានកម្មវិធីបញ្ជូន មានការរីកដុះដាលយ៉ាងឆាប់រហ័ស ទាំងការគ្រប់ដណ្តប់លើបរិមាណនិងភូមិសាស្រ្ត។

ដោយបារម្ភថា គ្មានប្រព័ន្ធណាមួយក្នុងពិភពលោកនេះរារាំងអ្នកចែកចាយមិនឱ្យចែកចាយសញ្ញាដែលមានកម្មវិធីបញ្ជូនតាមផ្កាយរណប ដែលមិនមែនជាឆន្ទៈរបស់អ្នកចែកចាយទាំងនេះ ហើយបារម្ភថាកង្វះខាតនេះអាចនឹងរារាំងចំពោះការប្រើប្រាស់ការផ្សព្វផ្សាយតាមផ្កាយរណប

ដោយទទួលស្គាល់ សារៈសំខាន់នៃផលប្រយោជន៍របស់អ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយក្នុងបរិបទនេះ

ដោយជឿជាក់ថា គួរបង្កើតប្រព័ន្ធអន្តរជាតិមួយ ដែលមានចែងពីវិធានការរារាំងអ្នកចែកចាយ មិនឱ្យចែកចាយសញ្ញាដែលមានកម្មវិធីបញ្ជូនតាមផ្កាយរណប ដែលមិនមែនឆន្ទៈរបស់អ្នកចែកចាយទាំងនេះ

ដោយយល់អំពី ភាពចាំបាច់ដែលមិនត្រូវប៉ះពាល់តាមរបៀបណាក៏ដោយដល់កិច្ចព្រមព្រៀងអន្តរជាតិដែលបានចូលជាធរមានរួចហើយ រាប់បញ្ចូលទាំងអនុសញ្ញាអន្តរជាតិស្តីពីទូរគមនាគមន៍ និងបទបញ្ជាស្តីពីវិទ្យុដែលជាឧបសម្ព័ន្ធក្នុងអនុសញ្ញានេះ ហើយជាពិសេសមិនត្រូវឱ្យប៉ះពាល់ជាដាច់ខាត ដល់ការទទួលយកយ៉ាងច្រើននូវអនុសញ្ញាទីក្រុងរ៉ូមចុះថ្ងៃទី២៦ខែតុលាឆ្នាំ១៩៦១ដែលការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ

បានយល់ព្រមដូចខាងក្រោម:

## មាត្រា១

ក្នុងគោលបំណងនៃអនុសញ្ញានេះ:

(i) "សញ្ញា" គឺជាឧបករណ៍ដែលបង្កើតដោយគ្រឿងអេឡិចត្រូនិច ហើយដែលអាចបញ្ជូនកម្មវិធីបាន។

(ii) "កម្មវិធី" គឺជាបណ្តុំនៃរូបភាព សម្លេង ឬរូបភាពនិងសម្លេង ដែលបានផ្សាយផ្ទាល់ឬបានថតទុកហើយដែលត្រូវបានបញ្ចូលក្នុងសញ្ញានានាដែលបានផ្សាយ ក្នុងគោលបំណងដើម្បីចែកចាយ

(iii) "ផ្កាយរណប" គឺជាឧបករណ៍ណាមួយក្នុងលំហក្រៅផែនដី ដែលអាចបញ្ជូនសញ្ញាបាន

(iv) "សញ្ញាដែលបានផ្សាយ" គឺជាសញ្ញាដែលមានកម្មវិធីណាមួយដែលបញ្ជូនទៅផ្កាយរណបឬឆ្លងតាមផ្កាយរណប

(v) "សញ្ញាបន្ត" គឺជាសញ្ញាដែលទទួលបានតាមរយៈការផ្លាស់ប្តូរចរិកលក្ខណៈបច្ចេកវិជ្ជានៃសញ្ញាដែលបានផ្សាយទោះបីបើមានឬគ្មានការភ្ជាប់បន្តណាមួយក៏ដោយ។

(vi) "អង្គការដើម" គឺរូបវន្តបុគ្គលឬនីតិបុគ្គលដែលសម្រេចថាតើសញ្ញាដែលបានផ្សាយនឹងមានកម្មវិធីអ្វីខ្លះ

(vii) "អ្នកចែកចាយ" គឺជារូបវន្តបុគ្គលឬនីតិបុគ្គល ដែលសម្រេចពីការបញ្ជូនសញ្ញាបន្តទៅកាន់សាធារណៈជនទូទៅឬ ផ្នែកណាមួយនៃសាធារណៈជន

(viii) "ការចែកចាយ" គឺជាប្រតិបត្តិការដែលអ្នកចែកចាយ បញ្ជូនសញ្ញាបន្តទៅកាន់សាធារណៈជនទូទៅ ឬផ្នែកណាមួយនៃសាធារណៈជន។

## មាត្រា២

(១) រដ្ឋហត្ថលេខីនីមួយៗសន្យាចាត់វិធានការចាំបាច់ដើម្បីរារាំង ការចែកចាយលើដែនដីឬចេញពីដែនដីរបស់ខ្លួននូវសញ្ញាដែលមានកម្មវិធី របស់អ្នកចែកចាយណាមួយដែលមិនមែនជាគោលដៅនៃសញ្ញាដែលបានផ្សាយទៅកាន់ផ្កាយរណប ឬឆ្លងតាមផ្កាយរណប។ កាតព្វកិច្ចនេះត្រូវអនុវត្ត នៅពេលដែលអង្គការដើមជាពលរដ្ឋនៃរដ្ឋហត្ថលេខីផ្សេងទៀត ហើយនៅពេលដែលសញ្ញាបានចែកចាយជាសញ្ញាបន្ត។

(២) ក្នុងរដ្ឋហត្ថលេខីណាមួយដែលមានការអនុវត្តវិធានការតាមកថាខណ្ឌ(១) ត្រូវកម្រិតរយៈពេល ហើយរយៈពេលនេះត្រូវកំណត់ក្នុងច្បាប់ជាតិរបស់ខ្លួន។ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីរយៈពេលនេះ ក្នុងពេលផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក ឬប្រសិនបើច្បាប់ជាតិចូលជា

ធរមានឬមានការផ្លាស់ប្តូរនាពេលបន្ទាប់ ត្រូវបានជូនដំណឹងក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីការចូលជាធរមានឬការកែប្រែច្បាប់នេះ។

(៣) កាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌ(១) មិនត្រូវអនុវត្តចំពោះការចែកចាយសញ្ញាបន្ត ដែលយកចេញពីសញ្ញាដែលបានចែកចាយរួចហើយដោយអ្នកចែកចាយដែលជាគោលដៅរបស់សញ្ញាដែលបានផ្សាយ។

## មាត្រា៣

អនុសញ្ញានេះមិនត្រូវអនុវត្ត នៅពេលសញ្ញាដែលបានផ្សាយដោយអង្គការដើមឬក្នុងនាមអង្គការដើម ក្នុងគោលដៅដើម្បីឱ្យសាធារណៈជនទូទៅទទួលបានផ្ទាល់ពីផ្កាយរណប។

## មាត្រា៤

រដ្ឋហត្ថលេខីមិនតម្រូវឱ្យអនុវត្តវិធានការទាំងឡាយដូចមានចែងតាមមាត្រា២(១) នៅពេលដែលសញ្ញាដែលបានចែកចាយលើដែនដីរបស់ខ្លួន ដោយអ្នកចែកចាយដែលមិនមែនជាគោលដៅនៃសញ្ញាដែលបានផ្សាយៈ

(i) មានភ្ជាប់នូវសម្រង់ខ្លីៗនៃកម្មវិធីដែលភ្ជាប់ដោយសញ្ញាដែលបានផ្សាយ ដោយរាប់បញ្ចូលទាំងសេចក្តីរាយការណ៍ស្តីពីបច្ចុប្បន្នភាព ប៉ុន្តែលុះត្រាតែការប្រើប្រាស់សេចក្តីសម្រង់នេះក្នុងទិសដៅព័ត៌មាន ឬ

(ii) ចំពោះអាគតដ្ឋាន មានភ្ជាប់សម្រង់ខ្លីៗនៃកម្មវិធីដែលភ្ជាប់ដោយសញ្ញាដែលបានផ្សាយ លុះត្រាតែអាគតដ្ឋាននេះស្របទៅនឹងការអនុវត្តទៀងត្រង់ ហើយត្រូវបានប្រើប្រាស់ក្នុងទិសដៅព័ត៌មានតែប៉ុណ្ណោះ ឬ

(iii) នៅពេលដែលដែនដីខាងលើ ជាដែនដីនៃរដ្ឋហត្ថលេខីមួយដែលត្រូវបានចាត់ទុកជាប្រទេសកំពុងអភិវឌ្ឍន៍ ស្របតាមការអនុវត្តដែលមានពីមុនរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ មានភ្ជាប់កម្មវិធីដែលភ្ជាប់ដោយសញ្ញាដែលបានផ្សាយ លុះត្រាតែ ការចែកចាយនេះធ្វើឡើងតែក្នុងគោលបំណងនៃការបង្រៀន រាប់បញ្ចូលទាំងការបង្រៀនក្នុងក្របខណ្ឌនៃការអប់រំយុវជន ឬការស្រាវជ្រាវវិទ្យាសាស្ត្រ។

## មាត្រា៥

រដ្ឋហត្ថលេខីមិនតម្រូវឱ្យអនុវត្តអនុសញ្ញានេះ ចំពោះសញ្ញាណាមួយដែលបានផ្សាយមុនអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនេះ។

## មាត្រា៦

អនុសញ្ញានេះមិនត្រូវបានបកស្រាយដើម្បីកម្រិត ឬធ្វើឱ្យប៉ះពាល់ដល់កិច្ចការពារចំពោះអ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម ឬអង្គភាពទូរផ្សាយ តាមច្បាប់ជាតិឬកិច្ចព្រមព្រៀងអន្តរជាតិឡើយ។

## មាត្រា៧

អនុសញ្ញានេះមិនត្រូវបានបកស្រាយ ដើម្បីការកម្រិតសិទ្ធិរដ្ឋហត្ថលេខីណាមួយក្នុងការអនុវត្តច្បាប់ជាតិរបស់ខ្លួន ដើម្បីរារាំងការរំលោភបំពានលើឯកាធិភាព។

## មាត្រា៨

(១) យោងតាមកថាខណ្ឌ(២)និង(៣) អនុសញ្ញានេះមិនអនុញ្ញាតឱ្យមានខរក្សាសិទ្ធិទេ។

(២) ត្រឹមថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៤ រដ្ឋហត្ថលេខីណាមួយដែលច្បាប់ជាតិរបស់ខ្លួនដែលបានចែងបែបនេះ តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ អាចចែងសម្រាប់គោលបំណងនៃច្បាប់នេះថា ពាក្យ"នៅពេលដែលអង្គការដើមជាពលរដ្ឋនៃរដ្ឋហត្ថលេខីផ្សេងទៀត" ដែលមានក្នុងមាត្រា២(១) ត្រូវបានចាត់ទុកថាជំនួសដោយពាក្យ"នៅពេលដែលសញ្ញាត្រូវបានផ្សាយពីដែនដីនៃរដ្ឋហត្ថលេខី ផ្សេងទៀត"។

(៣)

(ក) ត្រឹមថ្ងៃទី២១ខែឧសភាឆ្នាំ១៩៧៤ រដ្ឋហត្ថលេខីណាមួយដែលកម្រិតឬបដិសេធន៍កិច្ចការពារចំពោះការចែកចាយសញ្ញាដែលមានកម្មវិធីបញ្ជូនតាមមធ្យោបាយមានខ្សែ ខ្សែកាប ឬបណ្តាញផ្សព្វផ្សាយស្រដៀងគ្នាផ្សេងទៀត ទៅកាន់សមាជិកដែលចុះឈ្មោះ តាមសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ អាចប្រកាសថា លុះត្រាតែនិងនៅពេលដែលច្បាប់ជាតិរបស់ខ្លួនកម្រិត ឬបដិសេធន៍កិច្ចការពារខ្លួននឹងមិនអនុវត្តអនុសញ្ញានេះចំពោះការចែកចាយទាំងនេះ។

(ខ) រដ្ឋណាមួយដែលបានដាក់សេចក្តីជូនដំណឹងអនុលោមតាមអនុកថាខណ្ឌ(ក) ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ក្នុងរយៈពេល ៦(ប្រាំមួយ)ខែបន្ទាប់ពីការកែប្រែចូលជាធរមាន អំពីការកែប្រែណាមួយក្នុងច្បាប់ជាតិរបស់ខ្លួននៅពេលដែលខរក្សាសិទ្ធិតាមអនុកថាខណ្ឌនេះមិនអាចអនុវត្តបាន ឬមួយមានការកម្រិតវិសាលភាពច្រើន ។

## មាត្រា៩

(១) អនុសញ្ញានេះត្រូវតម្កល់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ អនុសញ្ញានេះនៅតែបើកចំហរសម្រាប់ការចុះហត្ថលេខា រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៥ ដោយរដ្ឋណាមួដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ភ្នាក់ងារឯកទេសណាមួយដែលមានទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ ឬភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។

(២) អនុសញ្ញានេះត្រូវដាក់ឱ្យធ្វើសច្ចាប័នឬទទួលយក ដោយរដ្ឋហត្ថលេខីទាំងឡាយ។ អនុសញ្ញានេះត្រូវបើកចំហរសម្រាប់ការចូលជាសមាជិក ដោយរដ្ឋណាមួយតាមកថាខណ្ឌ (១)។

(៣) លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការចូលជាសមាជិក ត្រូវតម្កល់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

(៤) នៅពេលដែលរដ្ឋមួយត្រូវចងភ្ជាប់ដោយអនុសញ្ញានេះ ត្រូវយល់ថា រដ្ឋនេះត្រូវចាត់ចែងផ្តល់អានុភាពទៅឱ្យបទប្បញ្ញត្តិនៃអនុសញ្ញានេះឱ្យស្របទៅនឹងច្បាប់ជាតិរបស់ខ្លួន។

## មាត្រា១០

(១) អនុសញ្ញានេះត្រូវចូលជាធរមាន ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីមានការតម្កល់លិខិតតុបករណ៍ទី៥(ប្រាំ)នៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក។

(២) សម្រាប់ការផ្តល់សច្ចាប័ន ការទទួលយក ឬការចូលជាសមាជិករបស់រដ្ឋនីមួយៗទៅនឹងអនុសញ្ញានេះ បន្ទាប់ពីការតម្កល់លិខិតតុបករណ៍ទី៥(ប្រាំ) នៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីតម្កល់លិខិតតុបករណ៍។

## មាត្រា១១

(១) រដ្ឋហត្ថលេខីណាមួយអាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

(២) ការប្រកាសដកខ្លួនចេញ ត្រូវមានអានុភាពអនុវត្តក្នុងរយៈពេល១២(ដប់ពីរ)ខែបន្ទាប់ពីកាលបរិច្ឆេទដែលទទួលបានសេចក្តីជូនដំណឹងតាមកថាខណ្ឌ(១)។

## មាត្រា១២

(១) អនុសញ្ញានេះត្រូវបានចុះហត្ថលេខាលើច្បាប់ដើមតែមួយគត់ជា ភាសាអង់គ្លេស ភាសាបារាំង ភាសារុស្ស៊ី និងភាសាអេស្ប៉ាញ។ អត្ថបទនៃភាសាទាំងបួននេះមានតម្លៃស្មើៗគ្នា។

(២) អត្ថបទផ្លូវការនានាជាភាសាអារ៉ាប់ ភាសាហូឡង់ ភាសាអាឡឺម៉ង់ ភាសាអ៊ីតាលី និងភាសាព័រទុយហ្កាល់ ត្រូវបង្កើតឡើងដោយអគ្គនាយកនៃអង្គការសហប្រជាជាតិ ដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក បន្ទាប់ពីកិច្ចពិភាក្សាយោបល់ជាមួយរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

(៣) អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវជូនដំណឹងទៅរដ្ឋទាំងឡាយ ដោយយោងតាមមាត្រា៩(១) ក៏ដូចជាអគ្គនាយកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ អគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ និងអគ្គលេខាធិការនៃសហភាពទូរគមនាគមន៍អន្តរជាតិអំពី:

- (i) ការចុះហត្ថលេខាលើអនុសញ្ញានេះ
- (ii) ការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការចូលជាសមាជិក
- (iii) កាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះតាមមាត្រា១០(១)
- (iv) ការដាក់សេចក្តីជូនដំណឹងណាមួយទាក់ទងនឹងមាត្រា២(២) ឬមាត្រា៨(២)ឬ(៣) រួមទាំងអត្ថបទនៃសេចក្តីជូនដំណឹងនេះផង
- (v) ការទទួលបានសេចក្តីជូនដំណឹងនៃការប្រកាសដកខ្លួនចេញ។

(៤) អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវបញ្ជូនអត្ថបទចម្លងដែលបញ្ជាក់ថាត្រឹមត្រូវចំនួន២(ពីរ)ច្បាប់នៃអនុសញ្ញានេះ ទៅកាន់រដ្ឋទាំងអស់ ដោយយោងតាមមាត្រា៩(១)។